**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៣៧. សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំកំពូល កម្ពុជា_ឡាវ_វៀតណាម លើកទី៦ (6th CLV Summit) កម្ពុជា_ឡាវ_មីយ៉ាន់ម៉ា_វៀតណាម លើកទី៥ (5th CLMV Summit) និងយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អាយេយ៉ាវ៉ាឌី_ចៅប្រាយ៉ា_មេគង្គ លើកទី៤ (4th ACMECS Summit) ឆ្នាំ ២០១០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក. ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំកំពូល កម្ពុជា-ឡាវ-វៀតណាម លើកទី៦ (6th CLV Summit) កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម លើកទី៥ (5th CLMV Summit) និងយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ លើកទី៤ (4th ACMECS Summit) ឆ្នាំ ២០១០ ដែលមានសមាសភាពដូចមានរាយនាមខាងក្រោម ÷

១-ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **ប្រធាន**

២-ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម **អនុប្រធាន**

៣-ឯកឧត្តម **ខៀវ កាញារិទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន **អនុប្រធាន**

៤-ឯកឧត្តម ថ្រាក់ សុខុន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៥-ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៦-ឯកឧត្តម ឡុង វិសាលោ រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៧-ឯកឧត្តម អ៊ុំ សារ៉ន រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៨-ឯកឧត្តម ម៉ៅ ហាវណ្ណាល់ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកម្ពុជា សមាជិក

៩-ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១០-ឯកឧត្តម វ៉ែត គុយសៀង រដ្ឋលេខាធិការ ក្រសួងសុខាភិបាល សមាជិក

១១-ឯកឧត្តម កែប ជុតិមា អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិក

១២-ឯកឧត្តម នាយឧត្តមសេនីយ៍ នេត្រ សាវឿន អគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក

១៣-ឯកឧត្តម នាយឧត្តមសេនីយ៍ សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៤-ឯកឧត្តម ជា សុខុម អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ គ.ជ.ប.អ សមាជិក

១៥-លោកជំទាវ ទូត បញ្ញា អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៦-ឯកឧត្តម ហោ សុធន អគ្គលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៧-លោក ឧត្តមសេនីយ៍ឯក ស៊ុំ ឆាន ប្រធាននាយកដ្ឋានអង្គរក្ស ក្រសួងមហាផ្ទៃ សមាជិក

១៨-លោក ទួន ស៊ីផាន់ ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

**ប្រការ ២ :** គណៈកម្មការរៀបចំកិច្ចប្រជុំកំពូលនេះ មានភារកិច្ច ដូចខាងក្រោម ÷

- រៀបចំកម្មវិធីនៃកិច្ចប្រជុំនិងពិធីការ ឱ្យបានសមស្រប
- លើកគម្រោងចំណាយសរុប តាមក្រុមជំនាញ ដើម្បីស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល
- សម្របសម្រួលនិងរៀបចំការពារសន្តិសុខ ជូនគណៈប្រតិភូ និងសមាជិកអង្គប្រជុំ ឱ្យមានសុវត្ថិភាពល្អ
- រៀបចំពិធីសំដែងសិល្បៈ វចាំប្រពៃណី ជូនគណៈប្រតិភូជាតិ និងអន្តរជាតិ
- សម្រួលចាត់ចែងកម្មវិធីដំណើរទស្សនាចរណ៍ ជូនគណៈប្រតិភូ ក្រោយកិច្ចប្រជុំចប់កម្មវិធី
- ជួយសម្របសម្រួលជាមួយប្រព័ន្ធឃោសនាជាតិនិងអន្តរជាតិ ដើម្បីផ្សព្វផ្សាយអំពីលទ្ធផលកិច្ចប្រជុំនេះ ។

**ប្រការ ៣ :** សមាជិកគណៈកម្មការខាងលើ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន អនុប្រធានគណៈកម្មការ និង ត្រូវធ្វើសេចក្តីរាយការណ៍ ជូនប្រធានគណៈកម្មការ អំពីលទ្ធផលការងាររបស់ខ្លួន ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកម្ពុជា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធានគណៈកម្មការរៀបចំបុណ្យជាតិនិងអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ